TRANSPARENCY INTERNATIONAL
the global coalition against corruption

# សន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយ ឆ្នាំ២០២០

## វិធីសាស្ត្រស្រាវជ្រាវ

លោក អ៊ឹម នរិន្ទ (នាយកកម្មវិធី)
អង្គការតម្លាភាពកម្ពុជា

ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១

# សន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយ ឆ្នាំ២០២០ គឺជា៖

TRANSPARENCY INTERNATIONAL
the global coalition against corruption

សន្ទស្សន៍ដែលផ្សំបញ្ចូលគ្នា (ប្រភពទិន្នន័យ១៣ផ្សេងៗគ្នា)

មានលក្ខណៈជាសកល (១៨០ប្រទេស/ដែនដី)

វាស់ស្ទង់ការយល់ឃើញ (អ្នកជំនាញ/ធុរជន)

ពីអំពើពុករលួយ (ការប្រើប្រាស់អំណាចខុសច្បាប់ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន)

នៅក្នុងវិស័យសាធារណៈ (មន្ត្រី និងស្ថាប័នសាធារណៈ)

# អ្វីដែលសន្ទស្សន៍ CPI ធ្វើការវាស់ស្ទង់

ប្រភពទិន្នន័យទាំងអស់របស់យើងធ្វើការវាស់ស្ទង់ពីអំពើពុករលួយក្នុងវិស័យសាធារណៈ ឬទិដ្ឋភាពជាក់លាក់មួយចំនួននៃអំពើពុករលួយក្នុងវិស័យសាធារណៈដូចជា៖

- សំណូក
- ការបង្វែរមូលនិធិសាធារណៈ
- ការប្រើប្រាស់តួនាទីដើម្បីផលប្រយោជន៍ឯកជន
- បក្ខពួកនិយមនៅក្នុងស្ថាប័នរដ្ឋ
- ឥទ្ធិពលរបស់ធុរជនទៅលើមន្ត្រីសាធារណៈ
- លទ្ធភាពរបស់រដ្ឋាភិបាលក្នុងការអនុវត្តយន្តការសុចរិតភាព
- ការផ្តន្ទាទោសប្រកបដោយប្រសិទ្ធភាពលើមន្ត្រីសាធារណៈដែលប្រព្រឹត្តអំពើពុករលួយ
- បែបបទរដ្ឋបាល និងការិយាធិបតេយ្យហួសហេតុ
- ការមានគ្រប់គ្រាន់នូវច្បាប់ស្តីពី ការបញ្ចេញព័ត៌មានហិរញ្ញវត្ថុ និងការបញ្ចៀសទំនាស់ផលប្រយោជន៍ និងសិទ្ធិទទួលបានព័ត៌មាន
- ការគាំពារផ្នែកច្បាប់ចំពោះបុគ្គលរាយការណ៍ អ្នកកាសែត និងអ្នកស៊ើបអង្កេត

# អ្វីដែលសន្ទស្សន៍ CPI មិនធ្វើការវាស់ស្ទង់

ដោយផ្អែកលើលក្ខណៈ សម្បត្តិដែលមាននៅក្នុងប្រភពទិន្នន័យរបស់យើង ចំណុចខាងក្រោមនេះមិនត្រូវបានគ្របដណ្តប់នៅក្នុងសន្ទស្សន៍ CPI ទេ៖

- ការយល់ឃើញ ឬបទពិសោធន៍របស់ប្រជាពលរដ្ឋទាក់ទងនឹងអំពើពុករលួយ
- ការគេងបន្លំពន្ធ
- រំហូរហិរញ្ញវត្ថុទុច្ចរិត
- អ្នកដែលអាចជំរុញឱ្យមានអំពើពុករលួយ (មេធាវី គណនេយ្យករ ទីប្រឹក្សាហិរញ្ញវត្ថុជាដើម)
- ការលាងលុយកខ្វក់
- អំពើពុករលួយក្នុងវិស័យឯកជន
- សេដ្ឋកិច្ចនិងទីផ្សារក្រៅផ្លូវការ

# វិធីសាស្ត្រ - ដំណាក់កាល

**ជំហានទី១** ជ្រើសរើសប្រភពទិន្នន័យ

**ជំហានទី២** កំណត់មាត្រដ្ឋានទិន្នន័យឡើងវិញ

**ជំហានទី៣** គណនារកមធ្យមភាគ

**ជំហានទី៤** រាយការណ៍ពីភាពមិនច្បាស់លាស់

# វិធីសាស្ត្រ - ប្រភពទិន្នន័យ

## អ្វីដែលធ្វើឱ្យប្រភពទិន្នន័យអាចប្រើបាន?

- ទំនុកចិត្តលើវិធីសាស្ត្រស្រាវជ្រាវ និងកិត្តិនាមរបស់ស្ថាប័នដែលធ្វើការស្រាវជ្រាវ
- ទិន្នន័យដែលមានគោលគំនិតស៊ីចង្វាក់គ្នា
- ការសិក្សាបែបបរិមាណវិស័យ
- អាចប្រៀបធៀបរវាងប្រទេសជាច្រើនបាន
- មានទិន្នន័យសម្រាប់ប្រៀបធៀបនឹងឆ្នាំផ្សេងទៀត

TRANSPARENCY INTERNATIONAL
the global coalition against corruption

THE WORLD BANK
IBRD • IDA | WORLD BANK GROUP

FREEDOM HOUSE

The Economist INTELLIGENCE UNIT

World Justice Project

WORLD ECONOMIC FORUM

BertelsmannStiftung

# វិធីសាស្ត្រ - កំណាត់មាត្រដ្ឋានទិន្នន័យឡើងវិញ

ប្តូរត្រឡប់ទិន្នន័យ (ក្នុងករណីចាំបាច់)

- តួលេខទាប = ពុករលួយខ្លាំង
- តួលេខខ្ពស់ = ស្អាតស្អំខ្លាំង



កំណត់ស្តង់ដាពីទិន្នន័យដើម ទៅជាពិន្ទុ z

កំណត់ស្តង់ដាទិន្នន័យទៅជាមាត្រដ្ឋានសន្ទស្សន៍ CPI(០-១០០)

- បំប្លែងពីពិន្ទុ z ទៅជាមាត្រដ្ឋានពិន្ទុពី ០ ដល់១០០
- សម្រួលរបាយទិន្នន័យឱ្យពិន្ទុអតិបរមាត្រឹម១០០ និងអប្បបរមាត្រឹម០

# វិធីសាស្ត្រ - កំណត់មាត្រដ្ឋានទិន្នន័យឡើងវិញ



TRANSPARENCY INTERNATIONAL
the global coalition against corruption

# វិធីសាស្ត្រ - គណនាមធ្យមភាគ

យ៉ាងហោចណាស់មានប្រភពទិន្នន័យចំនួន៣សម្រាប់ប្រទេសនីមួយៗ

គណនាមធ្យមភាគពិន្ទុ

ប្រភពទិន្នន័យនីមួយៗមានតម្លៃស្មើៗគ្នា



# វិធីសាស្ត្រ - គណនាមធ្យមភាគ

| ប្រទេស x | ពិន្ទុ |
|---|---|
| គម្រោងនៃភាពផ្សេងគ្នានៃប្រជាធិបតេយ្យ | ៧១ |
| ចំណាត់ថ្នាក់ហានិភ័យប្រចាំប្រទេសស្ដីពីការយល់ដឹងជាសកល | ៦២ |
| គម្រោងយុត្តិធម៌ពិភពលោក | ៧១ |

$$\text{ពិន្ទុរបស់ប្រទេស X} = \frac{៧១+៦២+៧១}{៣}$$

$$= ៦៨$$

# វិធីសាស្ត្រ – រាយការណ៍ពីភាពមិនច្បាស់លាស់

**ដើម្បីកំណត់ភាពមិនច្បាស់លាស់នៅក្នុងពិន្ទុត្រូវ៖**

- គណនាវិធីដែលដោះស្រាយបម្រែបម្រួលនៃទិន្នន័យ
- រាយការណ៍ពីកម្រិតលម្អៀង
- គណនានូវចន្លោះជឿទុកចិត្ត ៩០%

# ការបកស្រាយលទ្ធផល

**ពិន្ទុ៖**

នៅលើមាត្រដ្ឋានពិន្ទុ ០-១០០ ដែល ០ មានន័យថាពុករលួយខ្លាំង ហើយ១០០គឺ ស្អាតស្អំខ្លាំង។

អនុញ្ញាតឱ្យមានការប្រៀបធៀបជាមួយនឹងពិន្ទុឆ្នាំមុនៗ (រវាងឆ្នាំ២០១២ ដល់២០២០)៖ ពិន្ទុរបស់ CPI ឆ្នាំ២០២០ អាចប្រៀបធៀបបានជាមួយពិន្ទុCPI រវាង៨ឆ្នាំមុន ហើយការប្រែប្រួលពិន្ទុអាចយកទៅបកស្រាយបាន។

**ចំណាត់ថ្នាក់៖**

ក្នុងចំណោមប្រទេស/ដែនដីសរុប១៨០លើពិភពលោក ការប្រែប្រួលលេខរៀងអាចបណ្តាលមកពី៖

ក) ការប្រែប្រួលពិន្ទុCPIសម្រាប់ប្រទេសណាមួយរវាងឆ្នាំមួយទៅឆ្នាំមួយទៀត

ខ) ការប្រែប្រួលពិន្ទុរបស់ប្រទេសផ្សេងទៀតដែលត្រូវបានបញ្ចូលនៅក្នុងសន្ទស្សន៍CPI

គ) ការបន្ថែមប្រទេស/ដែនដីទៅក្នុងសន្ទស្សន៍នេះ។

TRANSPARENCY INTERNATIONAL
the global coalition against corruption

# ហេតុអ្វីនៅតែត្រូវការសន្ទស្សន៍CPI

សវនកម្មឯករាជ្យបានបញ្ជាក់ឡើងវិញថា សន្ទស្សន៍CPI គឺជាសូចនាករសកលដ៏សំខាន់មួយសម្រាប់ហេតុផលដូចខាងក្រោម៖

**វិសាលភាព៖** សន្ទស្សន៍CPIគ្របដណ្តប់លើចំនួនប្រទេសបានច្រើនជាងទិន្នន័យនីមួយៗផ្សេងទៀត

**ទំនុកចិត្តផ្នែកស្ថិតិ៖** សន្ទស្សន៍CPIមានភាពប្រសើរជាងផលបូកនៃផ្នែករបស់វា ព្រោះវាទូទាត់បន្ថយភាពខុសឆ្គងពីលើប្រភពទិន្នន័យទាំងនោះ ដោយសន្ទស្សន៍CPIធ្វើការគណនាពិន្ទុជាមធ្យមទៅលើទិន្នន័យយ៉ាងហោចណាស់ ៣ផ្សេងគ្នា និងច្រើនរហូតដល់ទិន្នន័យ១៣។

**ភាពច្បាស់លាស់៖** មាត្រដ្ឋានពិន្ទុរបស់សន្ទស្សន៍CPI( 0-១00 )បង្ហាញពីភាពច្បាស់លាស់ជាងបើធៀបនឹងប្រភពទិន្នន័យផ្សេងទៀតដែលអាចមានមាត្រដ្ឋានពិន្ទុត្រឹម ១-៥ ឬ ១-៧ (ហើយដែលប្រទេសជាច្រើនត្រូវចាត់ថ្នាក់នៅលេខរៀងដូចៗគ្នា)

**អព្យាក្រឹតភាព៖** សន្ទស្សន៍CPIធ្វើការសំយោគនូវទស្សនៈផ្សេងៗគ្នាស្តីពីបញ្ហាអំពើពុករលួយក្នុងវិស័យសាធារណៈ វាក៏មានភាពអព្យាក្រឹតជាងផងដែរ នៅពេលគិតដល់របបនយោបាយផ្សេងៗ។